**សុន្ទរកថា**
**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង**
**ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ,**
**ថ្លែងក្នុងពិធីបិទ**
**សន្និបាតបូកសរុបការងារឆ្នាំ ២០២២ របស់សហព័ន្ធស្រូវអង្ករកម្ពុជា**
សណ្ឋាគារសូហ្វីតែលភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០២២

- *ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម;*
- *ឯកឧត្តម, លោកជំទាវ, លោកឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គ-សន្និបាទ ជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីរីករាយ ដោយបានមកចូលរួមជាអធិបតី ក្នុង **ពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ ២០២២ របស់សហព័ន្ធស្រូវអង្ករកម្ពុជា** ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសហព័ន្ធស្រូវអង្ករកម្ពុជា ដែលបានរៀបចំសន្និបាតនេះឡើង ដើម្បីបូកសរុបលទ្ធផលការងារ ដែលសហព័ន្ធស្រូវអង្ករកម្ពុជាសម្រេចបានក្នុងឆ្នាំកន្លងទៅ និង ដើម្បីកំណត់ទិសដៅ និង ផែនការឆ្ពោះទៅមុខ សំដៅឆ្លើយតបទៅនឹងការវិវត្តន៍យ៉ាងរហ័សនៃបរិការណ៍សង្គម-សេដ្ឋកិច្ច, ទាំងក្នុងក្របខណ្ឌតំបន់ និង សកល ។

ក្នុងរយៈពេលជិតមួយទសវត្សរ៍មកនេះ, សហព័ន្ធស្រូវអង្ករកម្ពុជាបានចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍវិស័យស្រូវអង្ករ ដែលធ្វើឱ្យវិស័យនេះមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និង ត្រូវបានទទួលស្គាល់នៅលើឆាកអន្តរជាតិ, ជាពិសេស, អង្ករក្រអូបប្រណិតពូជផ្ការំដួលរបស់កម្ពុជា បានជាប់ពានរង្វាន់ជាអង្ករដែលមានគុណភាពល្អនៅលើពិភពលោក ចំនួន ៥ លើក ដោយលើកទី ៥ គឺនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២២ កន្លងទៅថ្មីៗនេះ ។ ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងអាណត្តិកន្លងទៅ ព្រមទាំងក្រសួង-ស្ថាប័ន និង

ភាគីពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន ប្រកបដោយស្មារតីបុរេសកម្ម និង ការទទួលខុសត្រូវខ្ពស់; ហើយជាលទ្ធផល, សម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងកិច្ចអភិវឌ្ឍវិស័យស្រូវអង្ករកម្ពុជា ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមចូលរួមអបអរសាទរដល់លទ្ធផលនៃការបោះឆ្នោតដែលប្រព្រឹត្តទៅប្រកបដោយជោគជ័យ ក្នុងការជ្រើសរើសថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល, ប្រធាន និង សមាជិកនៃសហព័ន្ធស្រូវអង្ករកម្ពុជា សម្រាប់អាណត្តិទី ៤ ឆ្នាំ ២០២២-២០២៥ ។

**-ឯកឧត្តម, លោកជំទាវ, លោកឧកញ៉ា, លោក, លោកស្រី!**

ជាការពិត, លទ្ធផលដ៏ប្រសើរនេះមិនមែនកើតមានឡើងដោយចៃដន្យនោះទេ ពោលគឺកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា គួបផ្សំជាមួយនឹងការគិតគូរ និង ការយកចិត្តទុកដាក់ខ្ពស់ជាប់ជាប្រចាំពីសំណាក់រាជរដ្ឋាភិបាល ចំពោះការអភិវឌ្ឍវិស័យនេះ ។ រាជរដ្ឋាភិបាលកម្ពុជា, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និង ភាពប្រាកដនិយមខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, បានចាត់ទុកវិស័យស្រូវអង្ករជាវិស័យយុទ្ធសាស្ត្រដ៏សំខាន់, ទាំងក្នុងទិដ្ឋភាពសន្តិសុខស្បៀង និង ពាណិជ្ជូបនីយកម្ម, ដោយបានដាក់ឱ្យអនុវត្តនូវ **គោលនយោបាយជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ ឆ្នាំ ២០១០-២០១៥,** ដែលបានធ្វើឱ្យវិស័យស្រូវអង្ករកម្ពុជា មានសន្ទុះរីកចម្រើនយ៉ាងខ្លាំង ហើយការនាំចេញអង្ករទៅទីផ្សារអន្តរជាតិ មានការកើនឡើងគួរជាទីមោទនៈ ។ ឆ្លៀតក្នុងឱកាសនេះដែរ, ខ្ញុំក៏សូមថ្លែងនូវអំណរគុណចំពោះប្រទេសអូស្ត្រាលី ដែលបានផ្តល់ការគាំទ្រដល់វិស័យស្រូវអង្ករកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ រហូតដល់បច្ចុប្បន្ន និង សូមលើកទឹកចិត្តឱ្យបន្តការគាំទ្រនេះទៅមុខទៀត។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានផ្តល់កិច្ចអន្តរាគមន៍ជាច្រើន មានជាអាទិ៍៖ ការផ្តល់ហិរញ្ញប្បទានសម្បទាន តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ទៅរោងម៉ាស៊ីនកិនស្រូវ និង ក្រុមហ៊ុននាំចេញអង្ករ; ការផ្តល់ការលើកលែងពន្ធស្ទើរគ្រប់ប្រភេទ ដូចជា អាករលើតម្លៃបន្ថែម និង ពន្ធកាត់ទុកជាដើម ចាប់តាំងពីឆ្នាំ ២០១១ រហូតដល់បច្ចុប្បន្ន; ការផ្តល់កិច្ចសម្រួលពាណិជ្ជកម្ម, ឡូជីស្ទីក និង ការដឹកជញ្ជូនអង្ករនាំចេញទៅកាន់ទីផ្សារអន្តរជាតិ; ការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ជាពិសេស, ប្រព័ន្ធស្រោចស្រពខ្វាត់ខ្វែង ។ល។ មិនតែប៉ុណ្ណោះ, នាពេលប៉ុន្មានថ្ងៃថ្មីៗនេះ, ក្នុងគោលបំណងដើម្បីជំរុញការប្រមូលទិញស្រូវ និង ជួយរក្សាស្ថិរភាពតម្លៃស្រូវជូនប្រជាកសិករ, រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់ថវិកាបន្ថែមចំនួន ១០ លានដុល្លារអាម៉េរិក បន្ថែមពីលើមូលនិធិសម្រាប់ទិញស្រូវ ចំនួន ៨៣ លានដុល្លារអាម៉េរិក តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម សម្រាប់គាំទ្រដល់រោងម៉ាស៊ីនកិនស្រូវ និង ក្រុមហ៊ុន

កែច្នៃ និង នាំចេញអង្ករ ក្នុងការប្រមូលទិញស្រូវពីប្រជាកសិករតាមថ្លៃសមស្រប សំដៅបញ្ចៀស នូវការទម្លាក់ថ្លៃពីឈ្មួញកណ្ដាលមួយចំនួន ក្នុងខណៈដែលការប្រមូលផលស្រូវវស្សារបស់ប្រជាកសិករ មានបរិមាណច្រើន ក្នុងពេលដំណាលគ្នា ។

យើងពិតជាមានមោទនភាព ចំពោះវិស័យស្រូវអង្ករកម្ពុជា ដែល, ក្នុងឆ្នាំ ២០១០-២០២១, ទទួលបានលទ្ធផលយ៉ាងល្អប្រសើរ; ក្នុងនោះ, ផលិតកម្មស្រូវបានកើនឡើង ៥០% ពោលគឺ កើនពី **៨ លានតោន** ដល់ **១២ លានតោន**, ដែលជាហេតុធ្វើឱ្យកម្ពុជាមិនត្រឹមតែមានស្បៀង គ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងស្រុកប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងនៅសល់ស្រូវប្រមាណជាង **៥ លានតោន** ក្នុងមួយឆ្នាំ សម្រាប់កែច្នៃ និង នាំចេញទៅកាន់ទីផ្សារអន្តរជាតិផងដែរ ។ ទន្ទឹមនេះ, ការនាំចេញអង្ករកម្ពុជាបានកើនឡើងប្រមាណ **៣ ដង** ពោលគឺកើនពីជាង **២០ ម៉ឺនតោន** ដែលមានតម្លៃស្មើនឹង **១៣៩ លានដុល្លារអាមេរិក** ក្នុងឆ្នាំ ២០១២ រហូតដល់ជិត **៦២ ម៉ឺនតោន** ដែលមានតម្លៃស្មើនឹង **៥២៧ លានដុល្លារអាមេរិក** ក្នុងឆ្នាំ ២០២១ ។ ដោយឡែក, ក្នុងរយៈពេល ១០ ខែដើមឆ្នាំ ២០២២ នេះ, ការនាំចេញអង្ករគ្រប់ប្រភេទពីកម្ពុជាទៅកាន់ **៥៦ ប្រទេស** សម្រេចបានជិត **៥១ ម៉ឺនតោន** ដែលគិតជាទឹកប្រាក់សរុបមានចំនួនជិត **៣៧៣ លានដុល្លារអាមេរិក** ដែលមានកំណើន **10%** ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ។

**-ឯកឧត្តម, លោកជំទាវ, លោកឧកញ៉ា, លោក, លោកស្រី!**

ក្នុងបរិការណ៍ដែលពិភពលោកបាន និង កំពុងប្រឈមនឹងវិបត្តិស្បៀងអាហារ ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និង ការកើនឡើងថ្លៃនៃធាតុចូលកសិកម្ម ដែលបណ្ដាលមកពីភាពរអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ព្រមទាំងសង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន, វិស័យស្បៀងអាហារ ពិសេស ស្រូវអង្ករនឹងកាន់តែមានសារៈសំខាន់សម្រាប់កម្ពុជា, ទាំងក្នុងបច្ចុប្បន្ន និង អនាគត ។ ជាងនេះទៀត, ការបន្តផ្លាស់ប្ដូរកាន់តែលឿននូវនិម្មាបនកម្មពាណិជ្ជកម្មសកល, ការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម និង ទីផ្សារចំពោះទំនិញយុទ្ធសាស្ត្រ ដូចជា ស្បៀង, ព្រមទាំងនិន្នាការនៃការកើនឡើងតម្រូវការស្បៀងអាហារជាសកល, ក៏បាន និង កំពុងបង្កើនសក្ដានុពលអភិវឌ្ឍមួយកម្រិតទៀត ដល់វិស័យស្រូវអង្ករកម្ពុជាផងដែរ ។

ឈរលើមូលដ្ឋាននេះ, ខ្ញុំសូមគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តផ្ដល់អាទិភាពខ្ពស់ លើការជំរុញការអភិវឌ្ឍវិស័យស្រូវអង្ករកម្ពុជា ដែលជាវិស័យមួយដ៏សំខាន់ ក្នុងការធានាសន្តិសុខស្បៀងរបស់ជាតិ, ការគាំទ្រដល់កំណើនសេដ្ឋកិច្ច និង ការបង្កើតការងារជូនប្រជា-ពលរដ្ឋ ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលនឹងបន្តគាំទ្រវិស័យស្រូវអង្ករ តាមរយៈការដាក់ចេញនូវវិធានការចាំបាច់នានា តាមរយៈយន្តការមួយចំនួន រួមមាន៖ (១).ការបន្តផ្ដល់ការលើកទឹកចិត្តផ្នែកសារពើពន្ធដល់រោងម៉ាស៊ីនកិនស្រូវ និង ក្រុមហ៊ុននាំចេញអង្ករ; (២).ការបង្កើនការផ្ដល់

ហិរញ្ញប្បទានសម្បទាន; (៣).ការជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជា ប្រព័ន្ធដឹកជញ្ជូន, ឡូជីស្ទីក និង ប្រព័ន្ធស្រោចស្រព; (៤).ការពង្រឹងប្រសិទ្ធភាពនៃការសម្របសម្រួលស្ថាប័ន និង ការអនុវត្តគោលនយោបាយពាក់ព័ន្ធ; និង (៥).ការធ្វើពិពិធកម្មទីផ្សារ ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និង កិច្ចសហប្រតិបត្តិការទ្វេភាគីនានាជាមួយប្រទេសដៃគូពាណិជ្ជកម្ម ។ល។

ជាមួយគ្នានេះ, វិស័យឯកជនក៏មានតួនាទីសំខាន់ ក្នុងការចូលរួមអភិវឌ្ឍវិស័យស្រូវអង្ករកម្ពុជាឱ្យអស់សក្តានុពលផងដែរ ដែលនឹងរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ច និង លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាកសិករយើង ។ ក្នុងន័យនេះ, ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនជូនអង្គសន្និបាត, ជាពិសេស, ថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល និង ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជាដែលទើបត្រូវបានទទួលការជ្រើសតាំងក្នុងអាណត្តិទី ៤ ដូចខាងក្រោម៖

*ទី១.*ត្រូវបន្តពង្រឹងការអនុវត្ត **ផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល ៥ ឆ្នាំ (២០២៣-២០២៧)** ក្នុងការជំរុញការនាំចេញអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, និងជាពិសេស, បង្កើនសមត្ថភាពលើការស្រាវជ្រាវ និង ការ-វិភាគទីផ្សារស្រូវអង្ករ, ក្នុងតំបន់ និង សកល, ព្រមទាំងធ្វើការចែករំលែកព័ត៌មានអំពីទីផ្សារប្រកបដោយតម្លាភាព ។

*ទី២.*ត្រូវបង្កើនសាមគ្គីភាពផ្ទៃក្នុង ដោយប្រកាន់ខ្ជាប់នូវគោលការណ៍តម្លាភាព, យុត្តិធម៌ និង ការគោរពគ្នាទៅវិញទៅមក សំដៅបង្កើនអំណាចចរចា (bargaining power) ជាមួយអ្នកបញ្ជាទិញ, ពង្រឹងភាពប្រកួតប្រជែងជាមួយប្រទេសនាំចេញផ្សេងទៀត និង ពិនិត្យលទ្ធភាពក្នុងការរៀបចំយុទ្ធសាស្ត្រកំណត់ថ្លៃរួមមួយ ក្នុងក្របខណ្ឌសហព័ន្ធសម្រាប់លក់អង្ករទៅទីផ្សារអន្តរជាតិ ។

*ទី៣.*ត្រូវបន្តផ្សព្វផ្សាយម៉ាកអង្ករកម្ពុជានៅលើទីផ្សារអន្តរជាតិ និង ចាប់យកកាលានុវត្តភាពឱ្យអស់សក្តានុពលពីទីផ្សារ និង ពន្លឿនការធ្វើពិពិធកម្មទីផ្សារនាំចេញ ក្នុងក្របខណ្ឌកិច្ចព្រម-ព្រៀងពាណិជ្ជកម្មសេរីដែលកម្ពុជាមាន ជាអាទិ៍: ក្របខណ្ឌនៃ **កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន** និង **កិច្ចព្រមព្រៀងនៃភាពជាដៃគូរសេដ្ឋកិច្ចក្នុងតំបន់គ្រប់ជ្រុងជ្រោយ** (RCEP) ។

*ទី៤.*ត្រូវបន្តចូលរួមជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញផលិតកម្មពូជសុទ្ធ ដូចជា ស្រូវក្រអូប និង ស្រូវផ្ការំដួល ហើយធ្វើការផ្គត់ផ្គង់ទៅកសិករ និង សហគមន៍កសិកម្ម ក្នុងកម្រិតថ្លៃសមរម្យ តាមរយៈយន្តការនៃភាពជាដៃគូរវាងរដ្ឋ និង ឯកជន ។

*ទី៥.*ត្រូវបន្តពង្រឹងសមត្ថភាពរោងម៉ាស៊ីនកិនស្រូវ ក្នុងការបង្កើនប្រសិទ្ធភាពនៃការកែច្នៃអង្ករ, ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការរៀបចំផែនការអាជីវកម្ម; ព្រមទាំងពិនិត្យលទ្ធភាពក្នុងការ-

ប្របាច់បញ្ចូលគ្នា ឬសហការគ្នា ក្នុងខ្សែច្រវាក់ផ្គត់ផ្គង់រវាងរោងម៉ាស៊ីនកិនស្រូវ និង ក្រុមហ៊ុននាំចេញតូចៗ សំដៅបង្កើនឧត្តមភាពនៃសេដ្ឋកិច្ចមាត្រដ្ឋាន (Economic of Scale) ។

**ទី៦.** ត្រូវពង្រឹងការសម្របសម្រួលការអនុវត្តកសិកម្មតាមកិច្ចសន្យា រវាងរោងម៉ាស៊ីនកិនស្រូវ, ក្រុមហ៊ុននាំចេញអង្ករ និង សហគមន៍កសិកម្ម ព្រមទាំងជំរុញកិច្ចសហការជាមួយភាគីពាក់ព័ន្ធនានា ពិសេស ជាមួយដៃគូអភិវឌ្ឍន៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, និង រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់នូវជំនួយបច្ចេកទេស និង ការផ្ទេរបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍកសិដ្ឋានខ្នាតតូច និង ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល, បច្ចេកទេសថ្មីៗ និង នវានុវត្តន៍ផ្សេងៗ ក្នុងការសម្របខ្លួន និង ពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងបង្កើនផលិតភាពបន្ថែម ។ និង

**ទី៧.** សហព័ន្ធស្រូវអង្ករកម្ពុជា និង រោងម៉ាស៊ីនកិនស្រូវទាំងអស់ ត្រូវសហការជិតស្និទ្ធ និង ខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាព ក្នុងការធ្វើការជាមួយក្រុមការងារអចិន្ត្រៃយ៍អន្តរស្ថាប័ន ដែលនឹងត្រូវបង្កើតឡើងក្នុងពេលឆាប់ៗ ដោយមានក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ និង ក្រសួងពាណិជ្ជកម្ម ជាសហប្រធាន និង មានការចូលរួមពីធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម, អាជ្ញាធរដែនដី និង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើការជាប្រចាំក្នុងការ-ជំរុញការទិញស្រូវពីប្រជាកសិករ, រក្សាស្ថិរភាពថ្លៃស្រូវ និង គ្រប់គ្រងសតិអារម្មណ៍ប្រជាកសិករនៅរាល់រដូវច្រូតកាត់ ដោយរៀបចំគិតគូរជាផែនការផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ តាំងពីពេលដាំដុះ, ពេលច្រូតកាត់, ការទិញ, ការដឹកជញ្ជូន, ការផ្តល់ហិរញ្ញប្បទាន និង យន្តការសម្របសម្រួលកំណត់ថ្លៃ ។

**-ឯកឧត្តម, លោកជំទាវ, លោកឧកញ៉ា, លោក, លោកស្រី!**

ជាថ្មីម្តងទៀត, ខ្ញុំសូមសម្តែងនូវការអបអរសាទរចំពោះ**លោកឧញ៉ា, លោក, លោកស្រី**ទាំងអស់ ដែលត្រូវបានសមាជិក-សមាជិកា ផ្តល់ទំនុកចិត្តបោះឆ្នោតជ្រើសតាំងជាប្រធាន និង សមាជិកក្រុមប្រឹក្សាភិបាល និង ប្រធានសហព័ន្ធសហព័ន្ធស្រូវអង្ករកម្ពុជា សម្រាប់អាណត្តិទី ៤ ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ថ្នាក់ដឹកនាំសហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងអាណត្តិថ្មីនេះ នឹងបន្តបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយឈរលើស្មារតីសាមគ្គីភាព និង តម្កល់ផលប្រយោជន៍រួមរបស់សហព័ន្ធជាធំ សំដៅសម្រេចឱ្យបាននូវចក្ខុវិស័យ និង បេសក-កម្មរបស់ខ្លួន ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, លោកឧកញ៉ា, លោក, លោកស្រី** ទាំងអស់ សូមសម្រេចប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺ៖ **អាយុ, វណ្ណៈ, សុខៈ, ពលៈ និង បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាស **បិទសន្និបាតបូកសរុបការងារ ឆ្នាំ ២០២២ របស់សហព័ន្ធស្រូវអង្ករកម្ពុជា** នាពេលនេះ ៕

**សូមអរគុណ!**